# វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី១៤ ខែធ្នូ ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការតាំងពិពណ៌ការនាំចេញ នាំចូល ពង្រឹងបណ្តាញពាណិជ្ជកម្ម
- ការនាំចេញអង្ករបស់កម្ពុជា បានធ្លាក់ចុះ១៣ភាគរយ
- សេដ្ឋកិច្ចវៀតណាមរីកចម្រើន ប៉ុន្តែហានិភ័យមានការកើនឡើង
- លោក ត្រាំ និយាយថា ប្រធានធនាគារសហព័ន្ធមិនគួរតម្លើងអាត្រាការប្រាក់ទេ

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការតាំងពិពណ៌ការនាំចេញ នាំចូល ពង្រឹងបណ្តាញពាណិជ្ជកម្ម

ការតាំងពិពណ៌ប្រចាំឆ្នាំលើកទី១៣ ទាក់ទងនឹងការនាំចេញ នាំចូលកម្ពុជា និងខេត្តមួយផលិតផលមួយ ត្រូវបានប្រារព្ធឡើងកាលពីសប្តាហ៍មុន ក្នុងគោលដៅលើកកម្ពស់ផលិតផលក្នុងស្រុក និងឱកាសនាំចេញ នាំចូលនានា។

ពិពណ៌ពាណិជ្ជកម្មនេះ ត្រូវបានជំរុញដោយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយចាត់ថាជាឱកាសមួយដើម្បីពង្រីកពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា និងលើកទឹកចិត្តដល់ការវិនិយោគ ជាពិសេសពីវិស័យឯកជន។

រដ្ឋាភិបាលខ្លួនឯងក៏កំពុងធ្វើឲ្យការចំណាយទៅលើឡូជីស្ទីក (ប្រតិបត្តិការដឹកជញ្ជូន) មានភាពប្រសើរឡើង តាមរយៈការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធ និងកាត់បន្ថយតម្លៃថាមពល។

### ការនាំចេញអង្ករបស់កម្ពុជា បានធ្លាក់ចុះ ១៣ភាគរយ

យោងតាមលេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បែបបទនាំចេញអង្ករ បានឱ្យដឹងថា៖ ការនាំចេញអង្ករបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ បានធ្លាក់ចុះ ១៣ភាគរយ ក្នុងរយៈពេល១១ខែដំបូងក្នុងឆ្នាំ២០១៨ ពោលគឺពី ៥៦២,២៣៧ តោន មក ៤៩៧,២៤០ តោន។

ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា បានអះអាងថា ការធ្លាក់ចុះនេះគឺដោយសារតែការប្រកួតប្រជែងថ្លៃជាមួយបណ្តាលប្រទេសជិតខាង និងការខ្វះអង្ករបម្រុងទុកសម្រាប់ការនាំចេញ។

## តារាងប្រចាំសប្តាហ៍៖ ចំណាត់ថ្នាក់ប្រាក់កម្ចីតាមប្រភេទអាជីវកម្មឆ្នាំ២០១៧

បើយោងទៅតាម របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា នៅក្នុងឆ្នាំ២០១៧ ប្រទេសកម្ពុជាមានស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ចំនួន៧៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) ចំនួន០៧។ នៅក្នុងឆ្នាំ២០១៧ MFIs មានទ្រព្យសកម្មចំនួន២០ ៣១០ ប៊ីលានរៀល ដែលមានកំណើនស្មើនឹង៣១% នៃ ផ.ស.ស.។ រីឯ MDIs មានទ្រព្យសកម្មចំនួន១៧ ២៣៦,៤៤ ប៊ីលានរៀលមានកំណើនស្មើនឹង៣១% នៃ ផ.ស.ស. នៅក្នុងឆ្នាំ២០១៧។

តារាងសង្ខេបប្រចាំសប្តាហ៍នេះបង្ហាញពីស្ថិតិនៃកម្ចីរបស់ MDIs និងMFIs ទៅតាមវិស័យផ្សេងៗ។ ការផ្តល់ឥណទានសម្រាប់គ្រួសារមានចំនួនធំជាងគេស្មើរនឹង៣៤% នៃឥណទានសរុប ខណៈដែលឥណទានផ្តល់អោយវិស័យកសិកម្មឈរនៅលំដាប់ទីពីរមានចំនួន២៥%។

### ចំណាត់ថ្នាក់ប្រាក់កម្ចីតាមប្រភេទអាជីវកម្មឆ្នាំ២០១៧




ប្រភព៖ ធនាគារជាតិនៃកម្ពុជាឆ្នាំ២០១៨

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## សេដ្ឋកិច្ចវៀតណាមរីកចម្រើន ប៉ុន្តែហានិភ័យមានការកើនឡើង

សេដ្ឋកិច្ចរបស់ប្រទេសវៀតណាម ត្រូវបានគេព្យាករណ៍ថានឹងកើនឡើង ៦,៨% ក្នុងឆ្នាំ២០១៨ នេះបើយោងតាមការធ្វើបច្ចុប្បន្នភាពរបស់ធនាគារពិភពលោកលើការអភិវឌ្ឍសេដ្ឋកិច្ចនាពេលថ្មីៗនេះ។ កំណើនសេដ្ឋកិច្ចត្រូវបានគេរំពឹងថានឹងខ្ពស់ជាងការព្យាករណ៍របស់ធនាគារពិភពលោក ដែលមានត្រឹមតែ ៦,៣% សម្រាប់ទីផ្សារដែលកំពុងរីកចម្រើននៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។

កំណើនសេដ្ឋកិច្ចនេះ ត្រូវបានជំរុញដោយការកើនឡើងនូវតម្រូវការក្នុងស្រុក និងសន្ទុះនៃវិស័យផលិតកម្មដែលមានទិសដៅសម្រាប់ការនាំចេញ។ កំណើនសេដ្ឋកិច្ច ក៏ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះបន្តិចមកត្រឹម ៦,៦% នៅឆ្នាំ២០១៩ និង ៦,៥% នៅឆ្នាំ២០២០ ដោយសារតែការព្យាករណ៍ការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចពិភពលោក និងការប្រែប្រួលនៃហានិភ័យដូចជា៖ ភាពតានតឹងនៃពាណិជ្ជកម្មពិភពលោក និងការកាត់បន្ថយលំហូរចូលមូលធន។

# សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

## លោក ត្រាំ និយាយថាប្រធានធនាគារសហព័ន្ធ មិនគួរតម្លើងអត្រាការប្រាក់ទេ

ខណៈពេលសង្គ្រាមពាណិជ្ជកម្ម កំពុងគំរាមកំហែងប្រទេសចិន និងបណ្តាប្រទេសដទៃទៀតនោះ លោកត្រាំ បានទាមទារឲ្យរក្សាអត្រាការប្រាក់ទាប ដើម្បីទ្រទ្រង់សេដ្ឋកិច្ចអាមេរិក។ លោក ត្រាំ បាន ផ្តល់បទសម្ភាសន៍ផ្ទាល់មុខ ដល់សារព័ត៌មាន Reuters កាលពីថ្ងៃអង្គារ ដោយបានថ្លែងថា៖ ការតម្លើងអត្រាការប្រាក់នេះគឺជារឿង«ឆោតល្ងង់» ហើយលោកមិនយល់ស្របជាមួយនឹងការតម្លើងអត្រាការប្រាក់ដែលប្រកាសដោយ លោក ហ្សេរ៉ូម ផូវែល ដែលជាប្រធានធនាគារសហព័ន្ធ ដែលលោក ត្រាំ បានតែងតាំងនោះទេ។

# ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះរួមមាន៖ អាមេរិក ថៃ ជប៉ុន ហុងកុង និងតៃវ៉ាន់ ចេញសេចក្តីសម្រេចស្តីពីអត្រាការប្រាក់។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

<u>ថ្ងៃច័ន្ទ ទី១៧ ខែធ្នូ</u>

- ការនាំចេញទំនិញមិនមែនប្រេងរបស់សឹង្ហបុរី ខែវិច្ឆិកា
- តុល្យភាពថវិការបស់ឥណ្ឌូនេស៊ី ខែវិច្ឆិកា

<u>ថ្ងៃអង្គារ ទី១៨ ខែធ្នូ</u>

- ការវិនិយោគមូលប័ត្របំណុលបរទេសនៅអាមេរិក ខែតុលា
- សៀវភៅក្រហមរបស់សហរដ្ឋអាមេរិក សម្រាប់ថ្ងៃទី០៥ ខែតុលា
- អត្រាអត់ការងារធ្វើនៅហុងកុង ខែវិច្ឆិកា

<u>ថ្ងៃពុធ ទី១៩ ខែធ្នូ</u>

- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្ម ខែវិច្ឆិកា
- អត្រាអតិផរណានៅម៉ាឡេស៊ី ខែវិច្ឆិកា
- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់នៅថៃ
- គណនេយ្យចរន្តរបស់អាមេរិក ប្រចាំត្រីមាសទី៣ ឆ្នាំ ២០១៨

<u>ថ្ងៃព្រហស្បតិ៍ ទី២០ ខែធ្នូ</u>

- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់របស់ធនាគារសហព័ន្ធនៅអាមេរិក
- ការព្យាករណ៍របស់គណៈកម្មការសេដ្ឋកិច្ចទីផ្សារសេរីរបស់អាមេរិក
- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់នៅជប៉ុន
- តុល្យភាពនៃជញ្ជីងពាណិជ្ជកម្ម នៅប្រទេសថៃ ខែវិច្ឆិកា
- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់ របស់ឥណ្ឌូនេស៊ី
- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់របស់ហុងកុង

<u>ថ្ងៃសុក្រ ទី២១ ខែធ្នូ</u>

- សន្ទស្សន៍នៃតម្លៃអ្នកផលិតរបស់កូរ៉េខាងត្បូង ខែវិច្ឆិកា
- អត្រាអតិផរណានៅជប៉ុន ខែវិច្ឆិកា
- ប្រាក់ចំណូលរបស់បុគ្គលនៅអាមេរិក ខែវិច្ឆិកា
- ចំណាយរបស់បុគ្គលនៅអាមេរិក ខែវិច្ឆិកា
- អត្រាកំណើនរបស់ ផ.ស.ស. នៅអាមេរិកបំណាច់ត្រីមាសទី៣
- សេចក្តីសម្រេចស្តីពីអត្រាការប្រាក់របស់តៃវ៉ាន់